# ការរៀបចំគោលការណ៍ណែនាំជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ សម្រាប់ជនពិការ និងមនុស្សចាស់



ឯកសារនេះរៀបរាប់អំពីជំហាននិងការរៀនសូត្រសំខាន់ៗពីការរៀបចំគោលការណ៍ណែនាំស្តីពីការ ផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលក្នុងប្រទេសកម្ពុជា អស់រយៈពេលពីរឆ្នាំកន្លងមក។ ឯកសារនេះផ្តោតលើអង្គការមិនមែនរដ្ឋាភិបាល និង រដ្ឋាភិបាល នៅកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និង អន្តរជាតិ ដែលមានបំណងចង់ស្វែងយល់បន្ថែមទៀតអំពីរបៀបបង្កើតគោលការណ៍ណែនាំ និង ដឹកនាំការរៀនសូត្រជាក់ស្តែងអំពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានការរួមបញ្ចូល។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលប្រទេសអូស្ត្រាលី (DFAT) ដែលបានគាំទ្រ និងផ្តល់មូលនិធិសម្រាប់គម្រោងនេះ អង្គការCBMអូស្ត្រាលី ដែលបានផ្តល់ សេចក្តីព្រាងបឋមនៃគោលការណ៍ណែនាំនេះក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ដែលបានដឹកនាំយើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះមន្ទីរអភិវឌ្ឍន៍ជនបទ (PDRD) បណ្តាអង្គការដែលធ្វើការងារលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យទាំងអស់ អង្គការជនពិការ និងដៃគូ ដែលបានជួយតេស្ត សាកល្បងគោលការណ៍ណែនាំនេះ នៅក្នុងគម្រោងរបស់ពួកគេ និងបានផ្តល់មតិយោបល់ត្រឡប់ និងជំនាញឯកទេសដ៏មានតម្លៃរបស់ពួកគេ។

# សង្ខេបដំណើរការរៀបចំគោលការណ៍ណែនាំជាតិ ៖

## ផ្អែកលើបទពិសោធន៍ជាតិក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល

### ជំហានទី១ ៖ កិច្ចប្រជុំរៀបចំផែនការ

កិច្ចប្រជុំជាមួយក្រសួងអភិវឌ្ឍន៍ជនបទដើម្បីរៀបចំផែនការនិងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេស

គោលការណ៍នាំថ្នាក់ជាតិត្រូវបានរៀបចំសេចក្តីព្រាងដោយ CBM និង WaterAid

កិច្ចប្រជុំក្រុមការងាររៀនសូត្រអំពីគោលគំនិតការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលបង្ហាញអំពី TOR របស់ គោលការណ៍ណែនាំនិងបង្កើតក្រុមប្រឹក្សាយោបល់

គោលការណ៍ណែនាំជាតិត្រូវបានរៀបចំសេចក្តីព្រាងដោយCBM ក្រោយកិច្ចប្រជុំក្រុមការងារនិងចែករំលែកជាមួយក្រុមដើម្បីសុំការផ្តល់មតិយោបល់




### ជំហានទី២ ៖ ធ្វើតេស្តគោលការណ៍ណែនាំ



ធ្វើតេស្តសាកល្បងសេចក្តីព្រាងគោលការណ៍ណែនាំជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើផ្នែក ផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យក្នុងភាពជាដៃគូរជាមួយអង្គការជនពិការក្នុងខេត្តចំនួន៥លើវិស័យផ្គត់ផ្គង់ទឹកស្អាត CLTS និង BCC ។

### ជំហានទី៣ ៖ កិច្ចប្រជុំ ពិគ្រោះយោបល់ និង ពិនិត្យកែសម្រួលគោលការណ៍ណែនាំឡើងវិញ



ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រុមប្រឹក្សាសកម្មភាពជនពិការ ដើរតួនាទីដឹកនាំនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីពិភាក្សាអំពីគោលការណ៍ណែនាំ។ កិច្ចប្រជុំពិគ្រោះយោបល់មួយជាមួយមនុស្សចាស់ត្រូវបានរៀបចំឡើងដើម្បីប្រមូលយោបល់គ្រឡប់អំពីគោលការណ៍ណែនាំ។

### ជំហានទី៤ ៖ ពិនិត្យ សម្រេចទៅលើគោលការណ៍ណែនាំ

ច្របាច់បញ្ចូលរាល់យោបល់ត្រឡប់ទាំងអស់និងមតិយោបល់ពីក្រុមប្រឹក្សាយោបល់ព្រមទាំងមតិយោបល់ដែលទទួលបានតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់នានា។
គោលការណ៍ណែនាំនេះនឹងត្រូវបានពិនិត្យកែសម្រួលឡើងវិញ និង អនុម័តដោយក្រសួងអភិវឌ្ឍន៍ជនបទ មុនពេលផ្សព្វផ្សាយទូទាំងប្រទេស។



### ជំហានទី៥ ៖ ការផ្សព្វផ្សាយ



ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ដើរតួនាទីដឹកនាំក្នុងការផ្សព្វផ្សាយទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
ភាពជាដៃគូរជាមួយអង្គការ Epic Arts ដើម្បីផលិតភាពយន្តថ្មីៗនិងការសម្តែងដើម្បីគាំទ្រដល់ការផ្សព្វផ្សាយសាររបស់គោលការណ៍ណែនាំ។

## សេចក្តីផ្តើម

យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពក្នុងប្រទេសកម្ពុជា (CDHS)[១] ឆ្នាំ២០១៥ បានឲ្យដឹងថា សមាជិកគ្រួសារចាប់ពីអាយុ៥ឆ្នាំឡើង ចំនួន១០% មានពិការភាពយ៉ាងហោចណាស់ចំនួន១ប្រភេទ។ ជំរឿនឆ្នាំ២០០៨បានបង្ហាញឲ្យដឹងថា ពលរដ្ឋកម្ពុជាចំនួន ៦.៣៤%មានអាយុច្រើនជាង៦០ឆ្នាំ។ ក្រុមប្រជាជននេះកំពុងមានការកើនឡើង ហើយគេរំពឹងថានឹងមានចំនួនច្រើនជាងនេះស្ទើរតែ៣ដងនៅក្នុង រយៈពេលប៉ុន្មានទសវត្សរ៍ខាងមុខ[២] ។ ជនពិការនិងមនុស្សចាស់ជាច្រើនប្រឈមនឹងឧបសគ្គគួរឲ្យកត់សម្គាល់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេចំពោះការទទួលបានទឹកមានសុវត្ថិភាពនិងអនាម័យមូលដ្ឋាន (WASH)[៣] ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពទី៦ អំពាវនាវឲ្យមានការទទួលបានទឹកស្អាតនិងអនាម័យជាសកលសម្រាប់ជនគ្រប់រូបត្រឹមឆ្នាំ២០៣០។

រដ្ឋាភិបាលកម្ពុជាមានគោលបំណងសម្រេចឲ្យបាននូវការទទួលបានទឹកស្អាត និងអនាម័យជាសកលត្រឹមឆ្នាំ២០២៥។ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យជនបទ[៤] ផ្តល់ *"អាទិភាពជូនជនក្រីក្របំផុត និង ប្រជាពលរដ្ឋព្រមទាំងតំបន់ដែលទទួលបានការយកចិត្តទុកដាក់តិចបំផុត"* និងថ្លែងថា៖ *"ការអភិវឌ្ឍ និង ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ (RWSSH) ត្រូវមានលក្ខខណ្ឌស្របទៅនឹងច្បាប់ស្តីពីការការពារ និង ការលើកកម្ពស់សិទ្ធិជនពិការ។*

---

[១] វិទ្យាស្ថានជាតិស្ថិតិ (២០០៥) ការអង្កេតប្រជាសាស្ត្រ និង សុខភាពក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៤

[២] វិទ្យាស្ថានជាតិស្ថិតិ (២០១២) ប្រជាសាស្ត្រមនុស្សចាស់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០១២

[៣] របាយការណ៍របស់អង្គការ WaterAid ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យក្នុងប្រទេស កម្ពុជា ឆ្នាំ២០១៤

[៤] ក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៤៖ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការផ្គត់ផ្គង់ទឹក និងអនាម័យជនបទ (RWSSH) ២០១៤-២០២៥

*រាល់គម្រោង និង កម្មវិធីទាំងអស់ ត្រូវពិចារណាអំពីសេចក្តីត្រូវការរបស់ជនពិការ នៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោងឬកម្មវិធីរបស់ពួកគេហើយអង្គការជនពិការនឹងត្រូវបានដាក់បញ្ចូលឬមានតំណាងនៅក្នុងរាល់ដំណើរការពិគ្រោះយោបល់ និង គណៈកម្មាធិការនានា"*។ ដូច្នេះ វាមានភាពចាំបាច់ខ្លាំងណាស់ ដែលរាល់កិច្ចខិតខំផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យទាំងអស់ត្រូវឈោងចាប់ក្រុមទាំងនេះ។

ការសិក្សាកំណត់វិសាលភាពមួយស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលដែលធ្វើឡើងដោយអង្គការWaterAidក្នុងឆ្នាំ២០១៤បានកំណត់រកឃើញចន្លោះប្រហោងមួយនៅកម្រិតគោលនយោបាយទាក់ទងនឹងការអនុវត្តល្អក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនិងបានរកឃើញផងដែរអំពីកិច្ចសហការតិចតួចរវាងវិស័យផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យ និង វិស័យពិការភាព។ ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) បានដឹងអំពីជំនាញឯកទេសរបស់អង្គការ WaterAid លើផ្នែកសមធម៌និងការដាក់បញ្ចូលព្រមទាំងបានសុំជំនួយរៀបចំគោលការណ៍ណែនាំស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលពីអង្គការWaterAid។ *"គោលការណ៍ណែនាំជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យសម្រាប់ជនពិការ និងមនុស្សចាស់"* ឬ *"គោលការណ៍ណែនាំស្តីពីការផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល"* ត្រូវបានអភិវឌ្ឍន៍ឡើងដើម្បីផ្តល់មគ្គុទ្ទេសក៍ណែនាំដល់អ្នកពាក់ព័ន្ធគ្រប់រូបដែលធ្វើការងារនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យជនបទដើម្បីឲ្យជ្រើសរើស ប្រើប្រាស់វិធីសាស្រ្តដែលមានការដាក់បញ្ចូលនៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនិងការអនុវត្តកម្មវិធីនេះ។

## ការអនុវត្តជាជំហានៗ ៖ ការរៀបចំគោលការណ៍ណែនាំ

ការរៀបចំគោលការណ៍ណែនាំនេះមានពាក់ព័ន្ធការរៀបចំផែនការ ការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ ការធ្វើតេស្តសាកល្បងឧបករណ៍ និង វិធីសាស្រ្តនានា ការពិនិត្យកែសម្រួលឡើងវិញ និង ការពិនិត្យ សម្រេចទៅលើគោលការណ៍ណែនាំ។

### ជំហានទី១ ៖ ការរៀបចំផែនការដើម្បីរៀបចំគោលការណ៍ណែនាំ

**ការកសាងភាពជាដៃគូ**

កិច្ចប្រជុំមិនផ្លូវការមួយ រវាងអង្គការ WaterAid និងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានធ្វើឡើងជាលើកដំបូងដើម្បីរៀបចំផែនការឲ្យមានកិច្ចប្រជុំក្រុមការងារមួយ។ សកម្មភាពនេះបានអនុញ្ញាតឲ្យក្រសួងអភិវឌ្ឍន៍ជនបទទទួលបានរូបភាពទាំងស្រុងអំពីដំណើរការ និងដើរ តួនាទីដឹកនាំពីដំបូង។

អង្គការ WaterAid បានសហការជាមួយអង្គការ CBMអូស្ត្រាលីដែលជាស្ថាប័នមួយមានជំនាញឯកទេសផ្នែកដាក់បញ្ចូលពិការភាពដើម្បីរៀបចំសេចក្តីព្រាងបឋមនៃគោលការណ៍ណែនាំនេះ។ វាមានសារៈសំខាន់ក្នុងការពាំនាំជំនាញ ឯកទេសសកលព្រមទាំងបទពិសោធន៍និងការអនុវត្តល្អបំផុតនានា ទាក់ទងនឹងការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលពីប្រទេសដទៃទៀត។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំមិនផ្លូវការនេះ វាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីសេចក្តីត្រូវការក្នុងការបង្កើនការយល់ដឹងនិងចំណេះដឹងអំពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលក្នុងចំណោមមន្ត្រីរបស់ក្រសួងអភិវឌ្ឍន៍ជនបទនិងមន្ទីរអភិវឌ្ឍន៍ជនបទ (PDRD) មុនពេលកិច្ចប្រជុំក្រុមការងារនេះអាស្រ័យដោយវាគឺជាប្រធានបទថ្មីមួយសម្រាប់មនុស្សជាច្រើន។ ការបណ្តុះបណ្តាលមួយរយៈពេលកន្លះថ្ងៃស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលត្រូវបានផ្តល់ដោយអង្គការ WaterAid កាកបាទក្រហមអូស្ត្រាលី(ARC) និង អង្គការសេវាអភិវឌ្ឍន៍ជនពិការ (DDSP) ជូនដល់មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទនាយកដ្ឋានផ្គត់ផ្គង់ទឹកនិងថែទាំសុខភាពជនបទនិង មន្ទីរអភិវឌ្ឍន៍ជនបទ។



## ការបង្កើតក្រុមការងារ និង ការរៀបចំសេចក្តីព្រាងដំបូងនៃគោលការណ៍ណែនាំ

កិច្ចប្រជុំក្រុមការងារលើកដំបូងត្រូវបានសម្របសម្រួលដោយក្រសួងអភិវឌ្ឍន៍ជនបទ និង អង្គការ WaterAid និងរួមមានអ្នកចូលរួមជាង២០នាក់ដែលអញ្ជើញមកពីអង្គការដែលធ្វើការផ្នែកកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យនិង អង្គការដែលធ្វើការផ្នែកពិការភាព ស្ថាប័ន រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង អង្គការជនពិការ (DPOs)។ នៅដំណាក់កាលនេះវាមានសារៈសំខាន់ក្នុងការបង្កើតក្រុមសំខាន់ៗចំនួនពីររួមមាន ក្រុមការងារ និងក្រុមប្រឹក្សាភិបាល។ ក្រុមការងារបានធ្វើតេស្តសាកល្បង និង ពិនិត្យកែសម្រួលឡើងវិញទៅលើគោលការណ៍ណែនាំ ដោយឡែកក្រុមប្រឹក្សាយោបល់បានផ្តល់ដំបូន្មានបច្ចេកទេសទៅលើមាតិកា និង ដំណើរការ។

នៅក្នុងកិច្ចប្រជុំនេះ អង្គការមិនមែនរដ្ឋាភិបាល និង រដ្ឋាភិបាល បានឯកភាពធ្វើតេស្តសាកល្បង និង បង្កលក្ខណៈឲ្យអង្គការជនពិការបានចូលរួមក្នុងការធ្វើតេស្តនីមួយៗ ទៅលើផ្នែកខាងក្រោមនៃគោលការណ៍ណែនាំនេះ៖ កម្មវិធីសហគមន៍ដឹកនាំការអនុវត្តអនាម័យ (CLTS) ទីផ្សារ អនាម័យ និងការផ្គត់ផ្គង់ទឹកស្អាត។ក្រោយពេលបានបញ្ចូលមតិយោបល់ត្រឡប់ពីអ្នកចូលរួម និង ការិយាល័យប្រចាំប្រទេសដទៃទៀតរបស់ WaterAid អំពីមាតិកាសេចក្តីព្រាងគោលការណ៍ណែនាំដំបូង ត្រូវបានអភិវឌ្ឍន៍ឡើង ដោយមានកិច្ចគាំទ្របច្ចេកទេសពីអង្គការ CBMអូស្ត្រាលី និងបញ្ជូនទៅក្រុមប្រឹក្សាយោបល់ដើម្បីសុំការផ្តល់មតិយោបល់។

ជាពិសេស ការសុំមតិយោបល់ផ្តោតលើវិស័យដូចតទៅ៖ ការណែនាំអំពីការផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលសម្រាប់ជនពិការ និង មនុស្សចាស់ ចំណាត់ការសំខាន់ៗចំនួន៤ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល ការកំណត់អត្តសញ្ញាណជនពិការនិងមនុស្សចាស់ពីដំបូង នៃវដ្តកម្មវិធីផ្គត់ផ្គង់ទឹកស្អាតលើកកម្ពស់អនាម័យ កម្មវិធីCLTS ដែលមានការដាក់បញ្ចូល ការផ្សព្វផ្សាយអំពីអនាម័យ ការផ្គត់ផ្គង់ទឹកស្អាត ទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត និង កន្លែងលាងដៃដែលអាចចូលប្រើប្រាស់បាន និងការត្រួតពិនិត្យ និងវាយតម្លៃលើទិដ្ឋភាពដែលមានការដាក់បញ្ចូលនៃកម្មវិធីទឹកស្អាតនិង លើកកម្ពស់អនាម័យ។

WaterAid

## ជំហានទី២ ៖ ការធ្វើតេស្តសាកល្បងគោលការណ៍ណែនាំនៅក្នុងគម្រោងផ្គត់ផ្គត់ទឹកស្អាត និងលើកកម្ពស់អនាម័យ សហគមន៍

អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យបានស្ម័គ្រចិត្តធ្វើតេស្តសាកល្បងលើផ្នែកមួយចំនួននៃគោលការណ៍ណែនាំហើយកិច្ចប្រជុំរៀបចំផែនការដោយឡែកត្រូវបានធ្វើឡើងជាមួយអង្គការមិនមែនរដ្ឋាភិបាលនីមួយៗ។ នៅក្នុងកិច្ចប្រជុំនេះ ក្រុមការងារបានពិភាក្សាអំពី កាលវិភាគ ទីតាំង ឧបករណ៍កំណត់សម្គាល់ណែនាំ ដើម្បីជួយដល់ការធ្វើតេស្តទៅលើផ្នែកនីមួយៗ និង ទម្រង់សម្រាប់កត់ត្រាអំពីដំណើរការនៃការធ្វើតេស្ត។ ការរៀបចំផែនការក៏ពាក់ព័ន្ធផងដែរទៅនឹងការធានាថាអង្គការជនពិការក្នុងមូលដ្ឋានបានចូលរួម នៅក្នុងគ្រប់ដំណាក់កាលទាំងអស់ នៃការធ្វើតេស្ត។ វាមានសារៈសំខាន់ក្នុងការផ្តល់ការបណ្តុះបណ្តាល និង ណែនាំអំពីឧបករណ៍ជូនដល់ក្រុមការងារទទួលបន្ទុកការងារផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល មុនពេលធ្វើតេស្តដើម្បលើកកម្ពស់ ការយល់ដឹងអំពីការបញ្ចូលពិការភាព និង ការផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យ ដែលបង្កលក្ខណៈឲ្យគេអាចមានលទ្ធភាពទទួលបាន។ ការធ្វើតេស្តក៏បានបង្កើតផងដែរ នូវការតភ្ជាប់ទំនាក់ទំនងរវាងអង្គការជនពិការ និង មន្ទីរអភិវឌ្ឍន៍ជនបទព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើផ្នែកផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យ។ អង្គការកម្ពុជាដើម្បីកុមារនិងការអភិវឌ្ឍន៍(COCD) បានធ្វើការងារជាមួយក្រុមជនពិការជួយខ្លួនឯង ដើម្បីធ្វើតេស្តដំណើរការ CLTS ក្នុងអំឡុងពេលបំផុសនៅខេត្តកណ្តាល។ការធ្វើតេស្តបានផ្តោតលើការកំណត់រកគ្រួសារដែលមានជនពិការ តាមរយៈការសាកសួរសំនួរដូចតទៅ៖តើមាននរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នក មានការលំបាកក្នុងការមើល ការដើរ ការស្តាប់ ការប្រាស្រ័យទាក់ទង/ការយល់ ដែរឬទេ? មុនពេលធ្វើតេស្ត មេភូមិបានដឹងថាមានមនុស្សពីរនាក់ជាជនពិការ ប៉ុន្តែក្រោយពេលសាកសួរសំនួរទាំងនេះ គេបានកំណត់រកឃើញមនុស្ស ចំនួន ១០នាក់ដែលជាជនពិការ។ (សូមមើលរូបភាពទី១)

អង្គការយូនីសេហ្វ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង អង្គការជនពិការ និង ARC បាន សហការគ្នាដើម្បីធ្វើ តេស្តទៅលើការត្រួតពិនិត្យលើការផ្គត់ផ្គង់ទឹកស្អាតដោយប្រើប្រាស់ឧបករណ៍ពិនិត្យទៅលើការបង្កលក្ខណៈងាយស្រួលនិងសុវត្ថិភាព (ASA) ក្នុងខេត្តព្រៃវែង និងខេត្តសៀមរាប។



រូបភាពទី១ ៖ ផែនទីភូមិក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល
ឧបករណ៍ ASA នេះត្រូវបានប្រើប្រាស់ដើម្បីកំណត់រកថាតើផ្នែកណាខ្លះនៃហេដ្ឋារចនាសម្ព័ន្ធ ដែលងាយស្រួលប្រើប្រាស់និងផ្នែកណាខ្លះដែលពិបាកប្រើប្រាស់ព្រមទាំងអនុសាសន៍ដើម្បីកែលម្អទៅលើការបង្កលក្ខណៈងាយស្រួល។

(សូមមើលរូបភាពទី២ និងទី៣)



*រូបភាពទី២ ៖ ស្ត្រីចំណាស់ម្នាក់កំពុងប្រើប្រាស់ហេដ្ឋារចនាសម្ព័នផ្គត់ផ្គង់ទឹកក្នុងខេត្តសៀមរាប*



*រូបភាពទី៣ ៖ ជនពិការម្នាក់កំពុង ប្រើប្រាស់ពាងទឹក នៅឯផ្ទះរបស់គាត់ក្នុងខេត្តព្រៃវែង*

ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង និង អង្គការជនពិការ បានធ្វើតេស្តសាកល្បងទៅលើការជម្រុញអនុវត្តន៍ CLTS ជាមួយមនុស្សពេញវ័យនិងកុមារក្នុងខេត្តព្រៃវែង។ លទ្ធផលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានតភ្ជាប់ទំនាក់ទំនងជាមួយអង្គការជនពិការ ព្រមទាំងបានចែករំលែកបទពិសោធន៍អំពីចាប់ដៃគូរជាមួយអង្គការ

មិនមែនរដ្ឋាភិបាលដែលធ្វើការងារលើផ្នែកផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យនិង មន្ទីរអភិវឌ្ឍន៍ជនបទដទៃទៀតដើម្បីបញ្ចូលជនពិការទៅក្នុងការជម្រុញអនុវត្តន៍ CLTS ។ (សូមមើលរូបភាពទី៤)



*រូបភាពទី៤ ៖ ស្ត្រីចំណាស់ម្នាក់កំពុងដាក់រូបតំណាងលាមក នៅលើ "ផែនទីភូមិ" ក្នុងទីតាំងដែលគាត់បន្ទោបង់រាល់ថ្ងៃ ខេត្តកំពង់ចាម*



*រូបភាពទី៥ ៖ បុរសពិការជើងម្នាក់កំពុងអនុវត្តន៍លាងដៃ ខេត្តស្ទឹងត្រែង*

ដោយមានកិច្ចសហការជាមួយ Samaritan's Purse និង អង្គការជនពិការ គេបានផ្ញើសារជូនដើម្បីធានាថា អ្នកដែលមានបញ្ហាកំសោយអវៈយៈផ្សេងៗគ្នា ជាពិសេសអ្នកដែលមានបញ្ហាកំសោយផ្នែកសោតវិញ្ញាណ និង ចក្ខុវិញ្ញាណ អាចមានលទ្ធភាពទទួលបានព័ត៌មាននានា។ (សូមមើលរូបភាពទី៥)

ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ត្បូងឃ្មុំ និង កំពត និង អង្គការ SNV ព្រមទាំងអង្គការជនពិការ បានធ្វើតេស្តមុនពេលបំផុស CLTS ក្នុងខេត្តកំពង់ចាម និង កំពត។ គោលបំណងគឺដើម្បីពិនិត្យស្វែងរកអំពីរបៀបបញ្ចូលមនុស្សចាស់ និងជនពិការទៅក្នុងការពេលបំផុស។ ជាលទ្ធផល អង្គការជនពិការបានបញ្ចូលប្រធានបទស្តីពីការផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យ ទៅក្នុងផែនការសកម្មភាព និង កិច្ចប្រជុំរបស់ពួកគេ។ អង្គការជនពិការក៏បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើផ្នែកផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យមួយផងដែរដើម្បីផ្សព្វផ្សាយផលិតផលធុងចម្រោះទឹកដែលមានតម្លៃសមរម្យសម្រាប់ជនពិការ។ក្រោមភាពជាដៃគូជាមួយអង្គការជនពិការអន្តរជាតិ Handicap International និងអង្គការជនពិការបាន

ធ្វើការផ្សព្វផ្សាយជូនដល់ជនពិការនៅក្នុងសហគមន៍អំពីអណ្តូងទឹកដែលបង្កលក្ខណ:ឲ្យពួកគេអាចមានលទ្ធភាពប្រើប្រាស់បាន។ (សូមមើលរូបភាពទី៦ និងទី៧)



*រូបភាពទី៦ ៖ ក្រោយពេលជម្រុញការអនុវត្តន៍ កុមារបានសុំឲ្យឪពុកម្តាយរបស់ពួកគេសង់បង្គន់នៅឯផ្ទះ ខេត្តព្រៃវែង*



*រូបភាពទី៧ ៖ ការប្រើប្រាស់ឧបករណ៍ជម្រុញការអនុវត្តន៍ជាមួយសហគមន៍ និងជនពិការ ក្នុងខេត្តព្រៃវែង*

អង្គការ SNV មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពត និងអង្គការជនពិការបានធ្វើតេស្តទៅលើការពិនិត្យតាមដានសកម្មភាពបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល ((ODF)) ក្នុងខេត្តកំពត។គោលបំណងគឺដើម្បីធានាឲ្យមានការដាក់បញ្ចូលជនពិការទៅក្នុងដំណើរការពិនិត្យផ្ទៀងផ្ទាត់របស់ការពិនិត្យតាមដានសកម្មភាពបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF) តាមរយ:កិច្ចសម្ភាសន៍ជនពិការនិងការធានាថាពួកគេប្រើប្រាស់បង្គន់ដែលមានអនាម័យ។



*រូបភាពទី៨ ៖ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត កំពុងសម្ភាសន៍បុរសពិការម្នាក់ដែលប្រើប្រាស់រទេះរុញ ខេត្តកំពត*

(សូមមើលរូបភាពទី៨)

### ជំហានទី៣ ៖ ការពិនិត្យកែសម្រួលគោលការណ៍ណែនាំឡើងវិញ

**ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) កំពុងដឹកនាំកិច្ចពិគ្រោះយោបល់ ដើម្បីចែករំលែកលទ្ធផលពីការធ្វើតេស្តសាកល្បង**

នៅពេលដែលការធ្វើតេស្តបានបញ្ចប់សិក្ខាសាលាពិគ្រោះយោបល់មួយ សហការរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមប្រឹក្សាសកម្មភាពជនពិការ (ដោយមានកិច្ចគាំទ្របច្ចេកទេសពីអង្គការ WaterAid) មានគោលបំណងផ្តល់បច្ចុប្បន្នភាពជូនដល់អ្នកពាក់ព័ន្ធអំពីដំណើរការធ្វើតេស្តនិងទទួលបានគំនិតបន្ថែមដើម្បីកែលម្អ និង ពិនិត្យសម្រេចទៅលើគោលការណ៍ណែនាំនេះ។



រូបភាពទី៩ ៖ ក្រសួងអភិវឌ្ឍន៍ជនបទ សម្របសម្រួលសិក្ខាសាលាពិគ្រោះយោបល់មួយ

## ការបង្គលក្ខណៈឲ្យមនុស្សចាស់បានចូលរួមនៅក្នុងការរៀបចំគោលការណ៍ណែនាំ

រហូតមកទល់ពេលនេះនៅក្នុងដំណើរការមានការចូលរួមតិចតួចពីមនុស្សចាស់ហើយទស្សនៈរបស់ពួកគាត់មិនត្រូវបានយកមកពិចារណាឲ្យបានល្អិតល្អន់ឡើយ។ ដូច្នេះ អង្គការ WaterAid បានសហការជាមួយអង្គការ HelpAge រៀបចំឲ្យមានកិច្ចប្រជុំពិគ្រោះយោបល់មួយជាមួយសមាគមមនុស្សចាស់ (OPAs) បានបង្កើតនូវកិច្ចប្រជុំពិគ្រោះយោបល់មួយជាមួយសមាគមមនុស្សចាស់ (OPAs) ក្នុងខេត្តបាត់ដំបង ដើម្បីទទួលបានធាតុចូលរបស់ពួកគេទៅក្នុងគោលការណ៍ណែនាំនេះ សំដៅធានាឲ្យមានការគិតគូរពិចារណា និងដោះស្រាយសេចក្តីត្រូវការនិងបញ្ហារបស់ពួកគេ។



រូបភាពទី១០ ៖ ការថតរូបជាក្រុមនៅឯកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងខេត្តបាត់ដំបង

## ជំហានទី៤ ៖ ការពិនិត្យសម្រេចទៅលើគោលការណ៍ណែនាំ

ផ្អែកលើការផ្តល់មតិយោបល់ត្រឡប់ពីសិក្ខាសាលាពិគ្រោះយោបល់ និង ក្រុមប្រឹក្សាយោបល់គោលការណ៍ណែនាំជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និង ការលើកកម្ពស់អនាម័យសម្រាប់ជនពិការ និងមនុស្សចាស់ត្រូវបានពិនិត្យសម្រេចលើសំណៅជាភាសាខ្មែរ និងភាសាអង់គ្លេស ក្នុងឆ្នាំ២០១៦។ គោលការណ៍ណែនាំនេះបានទទួលការអនុម័តពីក្រសួងអភិវឌ្ឍន៍ជនបទហើយនឹងត្រូវបានប្រកាសផ្សព្វផ្សាយជាផ្លូវការក្នុងលក្ខណៈជាផ្នែកមួយនៃ

កញ្ចប់ឯកសារមគ្គុទ្ទេសក៍ណែនាំថ្មីមួយ ដើម្បីគាំទ្រដល់ការអនុវត្តន៍ផែនការសកម្មភាពជាតិថ្មីស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទ ឆ្នាំ២០១៩-២០១៨។

## ជំហានទី៥ ៖ ការផ្សព្វផ្សាយប្រកបដោយភាពច្នៃប្រឌិត

ខណៈពេលកំពុងរៀបចំគោលការណ៍ណែនាំនេះ អង្គការ WaterAid មានការជម្រុញលើកទឹកចិត្តឲ្យស្វែងរកវិធីប្រកបដោយភាពច្នៃប្រឌិតដើម្បីលើកកម្ពស់ការយល់ដឹងអំពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលនិងលើកកម្ពស់សារសំខាន់ៗពីគោលការណ៍ណែនាំនេះ។ អង្គការ WaterAid បានចាប់ដៃគូរជាមួយអង្គការ Epic Arts ដែលជាអង្គការសិល្បៈដែលមានការដាក់បញ្ចូលមួយដែលល្បីខាងប្រើប្រាស់ការសម្តែងដ៏ជក់ចិត្តនិងចម្រៀងដ៏មានភាពទាក់ទាញដើម្បីជំរុញឲ្យមានការដាក់បញ្ចូល។



រួមជាមួយនឹងក្រុមសិល្បករវ័យក្មេងចំនួន៥នាក់ អង្គការទាំងពីរនេះបានរៀបចំការសម្តែងផ្ទាល់មួយ និង កម្រងខ្សែភាពយន្តខ្លីមួយចំនួន សម្រាប់អ្នកអនុវត្តការងារមើលតាមទូរស័ព្ទទំនើបរបស់ពួកគេ។ ខ្សែភាពយន្តនីមួយៗឆ្លុះបញ្ចាំងអំពីសារសំខាន់ៗ ឬ ឧបករណ៍មួយដែលដកស្រង់ពីគោលការណ៍ណែនាំ ដូចជា របៀបធ្វើការងារជាដៃគូជាមួយអង្គការជនពិការ របៀបកំណត់រកជនពិការនៅក្នុងសហគមន៍ របៀបធ្វើការវិភាគរបាំងឧបសគ្គ និងរបៀបធ្វើការពិនិត្យទៅលើការបង្កលក្ខណៈងាយស្រួលនិងសុវត្ថិភាព។ ដំណើរការធ្វើការងាររួមគ្នាប្រកបដោយភាពច្នៃប្រឌិតរវាងអង្គការចំនួនពីរដើម្បីបញ្ជាក់អំពីឯកសារ និង

ពិនិត្យស្វែងរកការបៀបផ្សព្វផ្សាយអំពីសារទាំងនោះ ពិតជាទទួលបានផលគួរជាទីពេញចិត្ត និង មានភាពរីករាយ។

ដើម្បីមើលខ្សែភាពយន្តទាំងនេះ សូមស្វែងរកតាមរយៈគេហទំព័រ៖

https://www.youtube.com/playlist?list=PLc-oawSTlDS2ht3B_Es7MEr3acVo8geV3

## ពេលវេលានៃការអភិវឌ្ឍន៍គោលការណ៍ណែនាំជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យសម្រាប់ជនពិការ និង មនុស្សចាស់។

សម្រាប់អង្គការដែលកំពុងចាប់ផ្តើមបង្កើតកម្មវិធីអភិវឌ្ឍន៍ដែលរាប់បញ្ចូលជនពិការ និង មនុស្សចាស់ ជំហានទាំង៥ខាងក្រោមនេះគឺជាជំហានដ៏សមស្រប និង អាចអនុវត្តន៍បាន។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបអំពីជំហាននីមួយៗព្រមជាមួយនឹងក្របខ័ណ្ឌពេលវេលា។ សរុបមក ដំណើរការនេះមានរយៈពេលប្រមាណ ១៨ខែ។

**ការរៀបចំផែនការ**
(មេសា-មិថុនា ២០១៥)

- ❖ ភាពជាដៃគូរជាមួយក្រសួងអភិវឌ្ឍន៍ជនបទនិងអង្គការ CBM(អូស្ត្រាលី)
- ❖ កិច្ចប្រជុំក្រុមការងារ (បង្កើតក្រុមការងារនិងក្រុមប្រឹក្សាយោបល់៖ សមាជិកភាព តួនាទីនិងគោលបំណង)
- ❖ អភិវឌ្ឍន៍សេចក្តីព្រាងដំបូងនៃគោលការណ៍ណែនាំ

**ការធ្វើតេស្ត**
(មិថុនា-តុលា ២០១៥)

- ❖ ធ្វើតេស្តទៅលើឧបករណ៍និងវិធីសាស្ត្រទៅតាមគោលការណ៍ណែនាំជាក្រុមតូចៗ
- ❖ ក្រុមតូចៗនីមួយៗធ្វើការកត់ត្រាអំពីអ្វីដែលពួកគេបានរៀនសូត្រ អ្វីដែលដំណើរការទៅបានល្អនិងជាអ្វីដែលជាបញ្ហាប្រឈម រៀបចំយោបល់ត្រឡប់ចំពោះការផ្តល់អនុសាសន៍ឲ្យផ្លាស់ប្តូរ។

**ពិនិត្យកែសម្រួលឡើង វិញ**
(វិច្ឆិកា ២០១៥-កុម្ភ:)

- ❖ ការពិគ្រោះយោបល់ដើម្បីចែករំលែកអំពីលទ្ធផលបឋមពីការធ្វើតេស្ត (អ្នកពាក់ព័ន្ធនានានិងមនុស្សចាស់)
- ❖ ប្រមូលរាល់មតិយោបល់ត្រឡប់ពីការធ្វើតេស្ត
- ❖ បង្កើតសេចក្តីព្រាងគោលការណ៍ឡើងវិញ

**ពិនិត្យសម្រេច**
(ឧសភា-សីហា ២០១៦)

- ចែករំលែកសេចក្តីព្រាងលើកទីពីរនៃគោលការណ៍ណែនាំ និងមតិយោបល់ត្រឡប់
- ពិនិត្យសម្រេចទៅលើគោលការណ៍ណែនាំនិងរៀបចំផែនការផ្សព្វផ្សាយ
- ចាប់ដៃគូរជាមួយ Epic Arts សម្រាប់ការផ្សព្វផ្សាយប្រកបដោយភាពច្នៃប្រឌិត

**ការផ្សព្វផ្សាយ**
(ចាប់ពីខែកញ្ញា ឆ្នាំ២០១៦ តទៅ)

- ការអនុម័តពីក្រសួងអភិវឌ្ឍន៍ជនបទ
- ការផ្សព្វផ្សាយនិងដាក់ឲ្យអនុវត្តន៍

## ការរៀនសូត្រសំខាន់ៗ និង បញ្ហាប្រឈម

ការរៀនសូត្រសំខាន់ៗ ៖

### តួនាទីដឹកនាំរបស់រាជរដ្ឋាភិបាលមានសារៈសំខាន់ខ្លាំងណាស់ ៖

តួនាទីរបស់ក្រសួងអភិវឌ្ឍន៍ជនបទក្នុងការគ្រប់គ្រងដំណើរការអភិវឌ្ឍន៍គោលការណ៍ណែនាំមានសារៈសំខាន់ ខ្លាំងណាស់។ វានាំឲ្យមានអង្គការកាន់តែច្រើនចូលរួមជាមួយគម្រោង។ បន្ថែមពីនេះទៀត វាអនុញ្ញាតឲ្យគេ អាចធ្វើតេស្តគោលការណ៍ណែនាំនេះនៅក្នុងកម្មវិធីរបស់រដ្ឋាភិបាល។ ឧទាហរណ៍ ក្រសួងអភិវឌ្ឍន៍ជនបទ បានសហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីសម្របសម្រួលឲ្យមានសិក្ខាសាលាពិគ្រោះយោបល់ និងដើរតួនាទីនាំមុខនៅក្នុងដំណើរការទាំងមូល។ នាពេលថ្មីៗនេះមន្ត្រីរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានចូលរួមដឹកនាំដំណើរការរៀបចំគោលការណ៍ណែនាំដទៃទៀតប្រកបដោយជោគជ័យ និងមានទំនុកចិត្តចំពោះវិធីប្រសើរបំផុតក្នុងការ អនុវត្តន៍ដំណើរការនេះ។

### ការបង្កើនការយល់ដឹងគឺជាជំហានដំបូងដែលមិនត្រូវមើលរំលង៖

នេះគឺជាលើកទីមួយដែលមន្ត្រីផ្នែកផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យថ្នាក់ខេត្ត បានរៀនសូត្រអំពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលហើយវាមានសារៈសំខាន់ក្នុងការបង្កើន ការយល់ដឹងជាមុនអំពីបញ្ហារបស់ជន

ពិការ ក្នុងការទទួលបានការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យ មុនពេលធ្វើតេស្ត។ វាក៏បានជួយកសាងទំនាក់ទំនងនិងបទពិសោធន៍ការងាររវាងអង្គការជនពិការ និងមន្ទីរ/ក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងមនុស្សចាស់នៅពេលអនាគតផងដែរ។

ជនពិការដើរតួនាទីសកម្មនៅក្នុងដំណើរការសកម្មភាពរៀនសូត្រនាំឲ្យមានការយល់ដឹងកាន់តែជ្រាលជ្រៅក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់៖

តួនាទីរបស់អង្គការជនពិការ (DPOs) ដែលសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីដឹកនាំការធ្វើតេស្តមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កលក្ខណៈឲ្យមានការចូលរួមពីជនពិការ។ វាកសាងឲ្យមានការជឿជាក់ទុកចិត្តរវាងជនពិការ និង អ្នកសម្របសម្រួល។ វានាំឲ្យមានការចូលរួមកាន់តែច្រើនពីជនពិការនៅក្នុងការធ្វើតេស្ត។ វាក៏បានផ្តល់ឱកាសជូនអង្គការជនពិការ ក្នុងការតភ្ជាប់ទំនាក់ទំនងជាមួយក្រសួង/មន្ទីរអភិវឌ្ឍន៍ជនបទ សម្រាប់កិច្ចសហការនៅពេលអនាគតដើម្បីកែលម្អចំពោះការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យសម្រាប់ជនពិការផងដែរ។

**បញ្ហាប្រឈម៖**

ក្នុងអំឡុងពេលនៃដំណើរការអភិវឌ្ឍន៍ ក៏មានបញ្ហាប្រឈមមួយចំនួនផងដែរ៖

ដំណើរការនេះត្រូវចំណាយពេលវេលាច្រើន ៖

ពេលវេលាជាច្រើនបានចំណាយទៅលើការសម្របសម្រួលអ្នកពាក់ព័ន្ធជាច្រើនឲ្យចូលរួមធ្វើតេស្ត។ ជារួម ការរៀបចំគោលការណ៍ណែនាំនេះ បានចំណាយពេលស្ទើរតែពីរដងនៃពេលវេលាដែលបានប៉ាន់ស្មាន ពីដំបូង។ ការធ្វើតេស្តទៅលើផ្នែកផ្សេងៗគ្នា ត្រូវតែស្របទៅនឹងពេលវេលារបស់សកម្មភាពសហគមន៍អង្គការមិនមែនរដ្ឋាភិបាលដែលជាហេតុនាំឲ្យខកខានចំពោះ ការធ្វើតេស្តលើផ្នែកទីផ្សារអនាម័យ នៃគោលការណ៍ណែនាំ។

សម្ភារៈទំនាក់ទំនងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត (BCC) មិនមានការបង្កលក្ខណៈងាយស្រួល៖

សម្ភារៈ BBC រមែងតែងមិនបានបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកមិនអាចស្តាប់លឺ ឬ មើលមិនឃើញ។ វគ្គអប់រំអំពីអនាម័យកំពុងមានការលំបាកសម្រាប់មនុស្សចូលរួម

ដោយសារតែបញ្ហាកំសោយអវៈយវៈ ផ្សេងៗគ្នា ដែលអាចត្រូវការទទួលព័ត៌មានក្នុងទម្រង់ផ្សេងៗគ្នា និង កន្លែងប្រជុំ។

### អ្នកសម្របសម្រួលសហគមន៍ផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យមានចំណេះដឹងតិចតួចអំពីការដាក់បញ្ចូលបញ្ហាពិការភាព៖

អ្នកសម្របសម្រួលបានទទួលការបណ្ដុះបណ្ដាលដោយសង្ខេបមុនពេលធ្វើតេស្ត ប៉ុន្តែនៅពេលដែលពួកគេចូលទៅក្នុងវិស័យនេះ ពួកគេនៅតែយល់ឃើញថាមានការលំបាក។ ឧទាហរណ៍មួយ គឺនៅពេលដែលអ្នកសម្របសម្រួលម្នាក់បានជួបជាមួយអ្នកដែលមានបញ្ហាកំសោយសោតវិញ្ញាណ ហើយវាគឺជាលើកដំបូងរបស់គាត់ក្នុងការបោះ

## ការប្រែប្រួលនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យ

ជំហានដើម្បីបញ្ចូលអ្នកដែលមានបញ្ហាកំសោយសោតវិញ្ញាណ។

នៅក្នុងអំឡុងពេលនៃការរៀបចំគោលការណ៍ណែនាំ វាមានការប្រែប្រួលមួយចំនួនរួចទៅហើយនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យដូចជា៖

### បង្កើនការយល់ដឹងរបស់អង្គការមិនមែនរដ្ឋាភិបាល និង រដ្ឋាភិបាល អំពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូល៖

ក្រសួងអភិវឌ្ឍន៍ជនបទ កំពុងទទួលយកភាពជាម្ចាស់លើបញ្ហានេះ និងដឹកនាំសកម្មភាពថ្មីៗ។ បច្ចុប្បន្ន ក្រសួងអភិវឌ្ឍន៍ជនបទកំពុងបង្កលក្ខណៈឲ្យមានការចូលរួមពីអង្គការជនពិការនៅក្នុងការងាររបស់ពួកគេតាមរយៈការអនុញ្ញាតឲ្យជនពិការនិងអង្គការជនពិការចូលរួមនៅក្នុងកិច្ចប្រជុំនៅពេលបំផុស CLTS ។

### សកម្មភាពផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យដែលមានការដាក់បញ្ចូលកំពុងត្រូវបានអនុវត្តន៍ជាក់ស្តែងនៅមូលដ្ឋាន៖

ក្រសួងអភិវឌ្ឍន៍ជនបទនិងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើផ្នែកផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យបានរាយការណ៍ឲ្យដឹងថាពួកគេកំពុងបោះជំហានដើម្បីឲ្យមានការដាក់បញ្ចូលជនពិការ និងមនុស្សចាស់កាន់តែច្រើនឡើង។ ឧទាហរណ៍៖ ក្នុង

ខេត្តព្រៃវែង មន្ទីរអភិវឌ្ឍន៍ជនបទកំពុងរៀបចំផែនការតម្លើងអណ្តូងទឹកចំនួន៦ និងបច្ចុប្បន្នកំពុងពិចារណាអំពីរបៀបផ្លាស់ប្តូរបទដ្ឋានរចនាបរិវេណជុំវិញអណ្តូងទឹកដើម្បីបង្កលក្ខណៈងាយស្រួលប្រើប្រាស់ចំពោះជនដែលមានបញ្ហាកំសោយអវៈយវៈផ្សេងៗគ្នា។ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារលើផ្នែកផ្គត់ផ្គង់ទឹកស្អាត និង លើកកម្ពស់អនាម័យ កំពុងកាន់តែធ្វើការដាក់បញ្ចូលកាន់តែច្រើនឡើងនៅក្នុងអង្គការរបស់ពួកគេ៖

អង្គការទស្សនៈពិភពលោក បានរាយការណ៍ឲ្យដឹងថា ដោយសារតែការចូលរួមធ្វើតេស្តពួកគេបានបង្កលក្ខណៈឲ្យជនពិការចូលរួមនៅក្នុងដំណើរការរចនា ដើម្បីសាងសង់អណ្តូងស្នប់ចំនួន៥ នៅខេត្តព្រះវិហារ។ ការចូលរួមពីជនពិការបែបនេះ ក៏បានជួយឲ្យអង្គការទស្សនៈពិភពលោកយល់ដឹងអំពីការរចនាហេដ្ឋារចនាសម្ព័ន្ធ ផ្គត់ផ្គង់ទឹកដើម្បីឲ្យជនពិការនៅក្នុងសហគមន៍មានលទ្ធភាពអាចប្រើប្រាស់បានផងដែរ។

រូបថត៖

ក្របមុខ អង្គការ /WaterAidអ៊ុង គឹមអ៊ាន់

ទំព័រទី៥ និង ទី៧ ដល់ទី២២ អង្គការ/WaterAidផេង ផារ៉ូហ្ស៊ីន

ទំព័រទី១៥៖ អង្គការ /WaterAidសារុំ មនោរី

ក្រោហ្វិក ទំព័រទី២៖ អង្គការ /WaterAidសារុំ មនោរី

**www.wateraid.org/cambodia**
S.I. Building 3rd Floor, #93, Preah Sihanouk Blvd,
Sangkat Chaktomuk, Phnom Penh, Cambodia
Tel: +855 17 935 083

WaterAid is a registered charity: Australia: ABN 99 700 687 141. Canada: 119288934 RR0001. India: U85100DL2010NPL200169. Sweden: Org.nr: 802426-1268, PG: 90 01 62-9, BG: 900-1629. UK: 288701 (England and Wales) and SC039479 (Scotland). US: WaterAid America is a 501(c) (3) non-profit organization